ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៨១/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

## ជំនួបតាមទូរស័ព្ទរវាង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និង ឯកឧត្តមរដ្ឋមន្ត្រី Jean-Noël BARROT ស្តីពីជម្លោះព្រំដែនកម្ពុជា-ថៃ

នៅរសៀលថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសន្ទនាតាមទូរស័ព្ទជាមួយ **ឯកឧត្តម Jean-Noël BARROT** រដ្ឋមន្ត្រីក្រសួងអឺរ៉ុប និងការបរទេសនៃសាធារណរដ្ឋបារាំង អំពីបច្ចុប្បន្នភាពនៃជម្លោះព្រំដែនកម្ពុជា-ថៃ។

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណនិងកោតសរសើរចំពោះការបន្តគាំទ្រឥតងាករេរបស់បារាំង ចំពោះដំណោះស្រាយជម្លោះព្រំដែនកម្ពុជា-ថៃ ដោយសន្តិវិធី និងការគោរពច្បាប់អន្តរជាតិ ជាពិសេសកិច្ចព្រមព្រៀងបទឈប់បាញ់នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ និងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូនភាគីបារាំងអំពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃអរិភាពដែលកំពុងបន្តកើតមាន ដែលតម្រូវឱ្យមានការជម្លៀសជនស៊ីវិលកម្ពុជាប្រមាណជាងកន្លះលាននាក់ និងការបង្កឱ្យមានវិបត្តិមនុស្សធម៌យ៉ាងធ្ងន់ធ្ងរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មានប្រសាសន៍ថាការវាយប្រហារមិនរើសគោលដៅរបស់យោធាថៃ បានបំផ្លិចបំផ្លាញខ្ទេចខ្ទីនូវហេដ្ឋារចនាសម្ព័ន្ធស៊ីវិល និងបង្កការខូចខាតយ៉ាងដំណំដល់ប្រាសាទបុរាណកម្ពុជាមួយចំនួន រួមទាំងតំបន់បេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូផងដែរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថានការណ៍ដែលកាន់តែធ្ងន់ធ្ងរអាក្រក់ទៅ ដោយបានកត់សម្គាល់ថា ការវាយប្រហាររបស់យោធាថៃ ទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស បានវាតទីចូលជ្រៅមកក្នុងទឹកដីកម្ពុជារហូតដល់ចម្ងាយ ៩០គីឡូម៉ែត្រពីព្រំដែន ដែលជាការឈ្លានពានរបស់ថៃមកលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា ដែលជារដ្ឋសមាជិកអាស៊ានដូចគ្នា។

ក្នុងន័យនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីភាពចាំបាច់ក្នុងការបញ្ឈប់ជាបន្ទាន់នូវការឈ្លានពានប្រដាប់អាវុធដោយខុសច្បាប់ពីសំណាក់ប្រទេសថៃមកលើកម្ពុជា។

ក្នុងឱកាសកិច្ចសន្ទនានេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូន**ឯកឧត្តម Jean-Noël BARROT** អំពីលទ្ធផលនៃកិច្ចប្រជុំពិសេសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានស្តីពីស្ថានការណ៍បច្ចុប្បន្នរវាងកម្ពុជា និងថៃ ដែលបានប្រព្រឹត្តទៅនៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងតាមរយៈផ្លូវការទូត ដែលបានធ្វើឡើងដោយប្រទេសម៉ាឡេស៊ីក្នុងនាមប្រធានអាស៊ាន ក៏ដូចជាប្រទេសចិន តាមរយៈដំណើរទស្សនកិច្ចមកកម្ពុជារបស់

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ប្រេសិតពិសេសទទួលបន្ទុកកិច្ចការអាស៊ីនៃក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន ព្រមទាំងការអន្តរាគមរបស់សហរដ្ឋអាម៉េរិក ក្នុងគោលបំណងសម្រួលដល់ការបញ្ឈប់ជាបន្ទាន់នូវជម្លោះប្រដាប់អាវុធរវាងកម្ពុជានិងថៃនេះ។

ជាការឆ្លើយតប **ឯកឧត្តម** Jean-Noël BARROT បានកោតសរសើរចំពោះសេចក្តីថ្លែងការណ៍របស់ប្រធានអាស៊ាននៅក្នុងកិច្ចប្រជុំពិសេសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន ស្តីពីស្ថានការណ៍បច្ចុប្បន្នរវាងកម្ពុជា-ថៃ កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី ដែលបានសង្កត់ធ្ងន់លើការបន្តកិច្ចសន្ទនាឡើងវិញ ដើម្បីដោះស្រាយជម្លោះព្រំដែន។ **ឯកឧត្តម** បានស្វាគមន៍ចំពោះកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥នេះ ដែលជាជំហានវិជ្ជមានមួយឆ្ពោះទៅមុខ។ លើសពីនេះ **ឯកឧត្តម** Jean-Noël BARROT បានសម្តែងការគាំទ្ររបស់ប្រទេសបារាំងចំពោះរាល់កិច្ចផ្តួចផ្តើមរបស់ប្រទេសម៉ាឡេស៊ី ចិន និងសហរដ្ឋអាមេរិក ដើម្បីសម្រេចឱ្យបាននូវដំណោះស្រាយដោយសន្តិវិធី តាមរយៈផ្លូវការទូត។

ក្នុងអំឡុងពេលនៃការសន្ទនា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តម** Jean-Noël BARROT បានឆ្លៀតឱកាសផ្លាស់ប្តូរទស្សនៈដើម្បីពង្រឹងបន្ថែមនូវចំណងមិត្តភាពដ៏យូរអង្វែងរវាងកម្ពុជា និងបារាំង និងបានរំលឹកនូវដំណើរទស្សនកិច្ចជាប្រវត្តិសាស្ត្ររបស់លោកឧត្តមសេនីយ៍ឆាល ដឺ ហ្គោល មកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលពេលនោះ លោក បានថ្លែងសុន្ទរកថាដ៏ល្បីល្បាញ ដោយអំពាវនាវឱ្យមានការគោរពអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជា។

ជាកិច្ចបញ្ចប់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តឥតងាករេរបស់កម្ពុជា ចំពោះដំណោះស្រាយដោយសន្តិវិធី យុត្តិធម៌ និងចីរភាព ដោយឈរលើមូលដ្ឋានច្បាប់អន្តរជាតិ និងសន្ធិសញ្ញា ព្រមទាំងកិច្ចព្រមព្រៀងដែលមានស្រាប់។ **ឯកឧត្តម** បានសង្កត់ធ្ងន់លើតម្រូវការក្នុងការអនុវត្តឱ្យបានពេញលេញ ប្រកបដោយភាពស្មោះត្រង់ និងសុទ្ធចិត្តនូវបទឈប់បាញ់ជាបន្ទាន់ ការបញ្ឈប់អរិភាព និងការកសាងទំនុកចិត្តគ្នាទៅវិញទៅមកឡើងវិញ។ **ឯកឧត្តម** ក៏បានទាមទារឱ្យមានការដោះលែងទាហានកម្ពុជាដែលជាប់ឃុំទាំង១៨នាក់ ដូចមានចែងក្នុងសេចក្តីថ្លែងការណ៍រួមស្រាប់។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥